# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៦

១. **ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃព្រហស្បតិ៍ ៥កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣

២. **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

៣. **ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន២២រូប និងតាមប្រព័ន្ធអនឡាយចំនួន៣២រូប សរុបចំនួន៥៤រូប។

៤. **របៀបវារៈ៖**

៤.១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២- ពិភាក្សាស្តីពី សេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គលើកទី១ឆ្នាំ២០២៣ ដោយលោកវេជ្ជបណ្ឌិត **ហួត សេរីវង្ស** ប្រធាននាយកដ្ឋាន ទាក់ទង និងចលនាប្រភពធនធាន។

៤.៣- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជំងឺអេដស៍។

៥. **លទ្ធផល ៖**

**៥.១** ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី** ។

**អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៦ ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានមានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះ បានផ្ដោតលើការពិនិត្យ និងពិភាក្សា លើសេចក្ដីសម្រេច ដែលបានអនុម័តក្នុងកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៣ ដើម្បីដាក់ផែនការអនុវត្តទៅតាមស្ថាប័នពាក់ព័ន្ធ ឆ្ពោះទៅសម្រេចគោលដៅឈានទៅបញ្ចប់អេដស៍ក្នុងឆ្នាំ២០២៥។

**៥.២** សេចក្ដីសម្រេចនៃកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៣ មានដូចខាងក្រោម៖

- ជំរុញយុទ្ធសាស្ត្រឆ្ពោះទៅសម្រេចគោលដៅ៩៥ ទី១ (៩៥% ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ) តាមរយៈការជំរុញការងារបង្ការនៃការចម្លងមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាព និងការជំរុញលើកទឹកចិត្តអ្នកមានការសង្ស័យមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ឱ្យបានឆាប់រហ័ស។
- ជំរុញក្រសួងទេសចរណ៍ បន្តយន្តការជំរុញលើកទឹកចិត្តដល់គ្រប់គ្រឹះស្ថានកម្សាន្តសប្បាយ សណ្ឋាគារ និងកន្លែងកម្សាន្តនានានៅទូទាំងប្រទេស ឱ្យចូលរួមអនុវត្តគោលនយោបាយនៃការប្រើប្រាស់ស្រោមអនាម័យ១០០ភាគរយ ឱ្យបានទូលំទូលាយ។
- ជំរុញក្រសួងអប់រំ យុវជន និងកីឡា បង្កើនការងារអប់រំផ្សព្វផ្សាយការយល់ដឹងអំពី មេរោគអេដស៍ និងជំងឺអេដស៍ បានទូលំទូលាយនៅតាមសាលារៀន គ្រឹះស្ថានឧត្តមសិក្សា ទាំងរដ្ឋ និងឯកជន ដើម្បីការពារ និងកាត់បន្ថយការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមយុវជន។
- ជំរុញក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បង្កើនការងារអប់រំផ្សព្វផ្សាយការយល់ដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យបានទូលំទូលាយដល់កម្មករ កម្មការិនី និងនិយោជិត នៅតាមរោងចក្រ សហគ្រាស នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។
- ជំរុញមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ(NCHADS) នៃក្រសួងសុខាភិបាលបង្កើន និងពង្រីកតំបន់គ្របដណ្ដប់នៃសេវាផ្ដល់ឱសថការពារមេរោគអេដស៍ជាមុន (PrEP) នៅតាមបណ្ដារាជធានី ខេត្ត។
- គាំទ្រការដាក់ចេញគោលនយោបាយជាតិបញ្ចប់ជំងឺអេដស៍ នៅឆ្នាំ២០២៥ និងចីរភាពកម្មវិធីឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០២៣-២០២៨។

**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** បានធ្វើការបញ្ជាក់ថា ការប៉ាន់ប្រមាណថាមានអ្នកឆ្លងមេរោគអេដស៍ថ្មី ក្នុងឆ្នាំ២០២២ ដែលមានន័យថា មនុស្សប្រហែល៤នាក់ បានឆ្លងមេរោគអេដស៍ជារៀងរាល់ថ្ងៃ។៤

ការប៉ាន់ស្មានមេរោគអេដស៍ថ្មី បានបង្ហាញថា ការកើនឡើងសមាមាត្រនៃការឆ្លង មេរោគអេដស៍ថ្មីគឺស្ថិតក្នុងចំណោមបុរស និងក្មេងប្រុស ពួកគេមានចំនួន៧៩% នៃការឆ្លងមេរោគអេដស៍ថ្មីទាំងអស់ក្នុងឆ្នាំ២០២២។ តាមចំនួនប្រជាជន៨៣% នៃការឆ្លងមេរោគអេដស៍ថ្មី សរុបគឺស្ថិតក្នុងចំណោម ប្រជាជនគន្លឹះ បុរសរួមភេទជាមួយបុរស ស្ត្រីបំប្លែងភេទ អ្នកដែលប្រើប្រាស់និងចាក់ថ្នាំញៀន និងដៃគូផ្លូវភេទរបស់ពួកគេ។ សមិទ្ធិផលរបស់ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាគំរូ ក្នុងការសម្រេចបានខ្ពស់បំផុតនូវអត្រាទទួលសេវាព្យាបាល និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។ ហេតុដូច្នេះហើយ ទើបយើងទាំងអស់គ្នាត្រូវតែអនុវត្តតាមសេចក្ដីសម្រេច ដែលបានអនុម័តក្នុងកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២៣ ដើម្បីដាក់ផែនការអនុវត្តទៅតាមស្ថាប័នពាក់ព័ន្ធ ឆ្ពោះទៅសម្រេចគោលដៅឈានទៅបញ្ចប់អេដស៍ក្នុងឆ្នាំ២០២៥

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្ដល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្ដូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្ដល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមាន គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្ដើរៗជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍៕

ថ្ងៃសុក្រ ១៣កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

ទួន សៅរិទ្ធ

អ្នកធ្វើរបាយការណ៍

ស៊ុំ ផល្លា

**ប្រធានអង្គប្រជុំ**

**បណ្ឌិត ឈឹម ឃិនឌារ៉េត**